# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៦៧១/០៨ **គ.ជ.ប**

## ជម្រាបជូន

### លោកនាយកវិទ្យាស្ថានជាតិប្រជាធិបតេយ្យ សម្រាប់កិច្ចការអន្តរជាតិ

**កម្មវត្ថុ** : អំពីការរៀបចំកម្មវិធីកិច្ចពិភាក្សាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ របស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ ( NDI ) ។

**យោង** :
-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨
-Debate Schedule (TVK &RADIO) រៀបចំឡើងដោយ NDI
-សំណួររបស់មជ្ឈដ្ឋានកំរៀបចំឡើងដោយ NDI
-ពាក្យបណ្តឹងលេខ ១៥៨/កច/០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ របស់មេធាវីគណបក្សប្រជាជនកម្ពុជា ។

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបលោកនាយកជ្រាបថា បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់មេធាវីគណបក្សប្រជាជនកម្ពុជា ដែលបានប្តឹងមក គ.ជ.ប សុំឱ្យលុបចោលកម្មវិធីពិភាក្សាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ក្រោយពី គ.ជ.ប បានពិនិត្យពិចារណាយ៉ាងយកចិត្តទុកដាក់រួចមក គ.ជ.ប សម្រេចដូចខាងក្រោម ÷

- ជ្រើសរើសមជ្ឈដ្ឋានកំ ត្រូវមានការយល់ព្រមពីគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ។
- ប្រធានបទ ឬសំណួរសម្រាប់ការពិភាក្សាដែល NDI បានរៀបចំត្រូវមានការឯកភាពពីគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ។
- កម្មវិធីពិភាក្សានេះ ត្រូវគោរពតាមគោលការណ៍ស្មើភាព ដោយត្រូវអញ្ជើញគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតចូលរួម ។
- បន្ទាប់ពីថតកម្មវិធីពិភាក្សានេះរួច NDI ត្រូវស្នើសុំមក គ.ជ.ប ពិនិត្យសម្រេចជាមុនសិន ទើបអាចធ្វើ ការចាក់ផ្សាយបាន ។

អាស្រ័យហេតុនេះ សូមលោកនាយកជ្រាបតាមការគួរ ។

សូមលោកនាយក ទទួលនូវការរាប់អានអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៨

**ត.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

ទេព នីថា

**ចម្លងជូន**

-លោក បែនសុន សម័យ មេធាវីគណបក្សប្រជាជនកម្ពុជា

-ឯកសារ កាលប្បវត្តិ